ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ ៥៧

សាលាដំបូងរាជធានីភ្នំពេញ

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១២៤៤

ចុះថ្ងៃទី០៨-០៧-២០០៨

សាលក្រមលេខ ៦៦ ខ

ចុះថ្ងៃទី២០-០៧-២០០៩

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣។

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញ ថ្ងៃទី២៣-០៦-២០០៩ ដែលមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

**លោក** [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

**លោក** [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

**លោក** [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ១២៤៤ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ដែលមានជនជាប់ចោទ

-ឈ្មោះ [redacted] **ប៊ុនហាច** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] ភូមិ៦ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] ស ម្តាយឈ្មោះអ៊ុន ធី ស ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន។ សព្វថ្ងៃនៅក្រៅឃុំ ។

-**ត្រូវជាប់ចោទពីបទ: ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ** ប្រព្រឹត្តនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-០៥-២០០៨ តាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

**-មេធាវីការពារលោក [redacted] ជាវ៉ាត**

-និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **គង់** ភេទស្រី អាយុ៥៤ឆ្នាំ មានទីលំនៅផ្ទះលេខ២ ផ្លូវលេខ ២៤៧ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**-មេធាវីការពារ លោក [redacted] ចំពោះលោក [redacted] រិទ្ធិ**

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>

-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៨-០៧-០៨របស់ឈ្មោះ [redacted] គង់ ប្តឹងពីឈ្មោះ [redacted] ប៊ុនហាវដោយបញ្ជាក់ថា: កន្លងមកឈ្មោះ [redacted] ប៊ុនហាវតែងតែព្យាយាមលប់ប្រឡាយចាស់ជាច្រើនលើកដែលស្ថិតនៅលើដីកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែអាជ្ញាធរមូលដ្ឋានភូមិ សង្កាត់ និង ប្រជាពលរដ្ឋបានធ្វើការរាំងមិនឱ្យលប់លើប្រឡាយចាស់នេះទេ ដែល

អាសយដ្ឋាន អគារលេខ ២៥ ២៧ ផ្លូវលេខ ២១៧ ២១៣ សង្កាត់វាលវង់ ខណ្ឌ ៧ មករា ភ្នំពេញ ទូរសារ ទូរស័ព្ទ (៨៥៥) ២៣ ៨៨៥ ៩៦១ / ២៣ ៨៨៥ ៩៦២
Adress #25-27, Street 217-213 Sangkat vealvong Khan 7makara Phnom Penh, Cambodia Fax-Phone (855) 23 885 961 / 23 885 962

Scanned by CamScanner

ជាមូលដ្ឋានសំរាប់ទុកបញ្ចៀសទឹកជន់លិចពីខាងលើ ។ ប៉ុន្តែឈ្មោះ [redacted] ប៊ុនហាវក៏បានប្រព្រឹត្តសំរេចក្នុងការលប់ប្រឡាយចាស់ដែលនៅក្នុងដីរបស់ខ្លួនតាមបំណង ដោយមកជីកប្រឡាយថ្មីក្រៅដីរបស់ខ្លួនជំនួសវិញ ទង្វើបែប នេះដើម្បីកុំឱ្យខូចប្រយោជន៍របស់ខ្លួនក្នុងការបែងចែកដីជាឡូត៍ ព្រោះកន្លងមកមិនអាចធ្វើទៅបានដោយសារមានប្រឡាយចាស់នៅ ក្នុងដីដែលត្រូវសាងសង់បូរីទួលសង្កែ ។ ការជីកប្រឡាយថ្មីខាងក្រៅផ្ទះរបស់ខ្លួនបាន ធ្វើឱ្យប៉ះពាល់ ដល់ដីកម្មសិទ្ធិ របស់អ្នកដទៃជាច្រើន ដូចយ៉ាងនៅថ្ងៃ០៧-០៥-០៨ វេលាម៉ោង១:០០យប់ ឈ្មោះ [redacted] ប៊ុនហាវ និង គូកនបានមករំលោភជីកកកាយដី ដល់ដីកម្មសិទ្ធិរបស់ខ្លួនដែលមាន បណ្ដោយប្រហែល១០ម៉ែត្រ និង ទទឹងប្រហែល៨ ម៉ែត្រព្រមទាំងកំទេចរបង របស់ខ្លួនទាំងស្រុង ។ ក្នុងរឿងនេះខ្លួនសុំឱ្យផ្ដន្ទាទោសឈ្មោះ [redacted] ប៊ុនហាវនិងគូកនតាមច្បាប់ .សុំសំណងការខូចខាត និង ជម្ងឺចិត្តចំនួន១៥០.០០០ដុល្លាអាមេរិក ដប់ប្រាំម៉ឺនដុល្លា .សុំប្រគល់ដីដែលជាកម្មសិទ្ធិរបស់ខ្លួននិងសុំធ្វើរបងផ្ទះឱ្យខ្លួនវិញ ។

**-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៧ ខ ចុះថ្ងៃទី២៣-០៣-២០០៩ មានខ្លឹមសារដូចតទៅ:**

១-ផ្ដន្ទាទោសឈ្មោ [redacted] **ប៊ុហាច** ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០២ឆ្នាំ ពីរឆ្នាំ** តែទោសនេះត្រូវព្យួរមានរយៈពេលសាកល្បង ០៥ឆ្នាំ គិតពីសាលក្រមស្ថាពរ ពីបទៈធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃ ប្រព្រឹត្តនៅភូមិបឹងសាឡាង សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧-០៥-២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៥២ មាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ឱ្យឈ្មោះ [redacted] **ប៊ុនហាច** សងសំណងការខូចខាតនិងជម្ងឺចិត្តជាប្រាក់ចំនួន ៤០.០០០.០០០រៀល សែសិបលានរៀលទៅដើមចោទឈ្មោះ [redacted] គង់ នៅពេលសាលក្រមចូលជាស្ថាពរសំណើលើសពីនេះបដិសេធចោល ។

ក្នុងករណីជនជាប់ចោទគ្មានប្រាក់សងធនទណ្ឌទេ ត្រូវអនុវត្តការដាក់បង្ខំដល់រូបកាយតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះនិង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្ដឹង មេធាវីដើមបណ្ដឹង មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើលផ្លូវប្ដឹងទាស់និងប្ដឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

-បានឃើញពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី ២៣-០៤-២០០៩ របស់ឈ្មោះ [redacted] ប៊ុនហាវ ប្ដឹងទាស់និងសាលក្រមលេខ ៣៧ ខ ចុះថ្ងៃទី២៣-០៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

**<u>នាពេលសវនាការ</u>**

-ឈ្មោះ [redacted] គង់ ជាដើមបណ្ដឹងឆ្លើយថា: ខ្លួនសុំឱ្យតុលាការតំកល់សាលក្រមកំបាំងមុខ៣៧ ខ ចុះថ្ងៃទី២៣-០៣ ២០០៩ នៅដដែល ។

មេធាវី [redacted] ៣ ធ្វើសេចក្ដីសន្និដ្ឋាន:គាត់ពិតជាបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិកូនក្ដីខ្លួនប្រាកដមែន អ្នកបំផ្លាញនោះគឺលោក [redacted] ប៊ុនហាវ ពុំមែនខាងក្រសួងធនធានទឹកទេ ។ ខ្លួនសុំតំកល់សាលក្រមកំបាំងមុខលេខ ៣៧ ខ ចុះថ្ងៃទី២៣-០៣-២០០៩ នៅដដែល ។

មេធាវី [redacted] រិទ្ធិ ធ្វើសេចក្ដីសន្និដ្ឋាន: ក្រសួងធនធានទឹកជាអាជ្ញាកណ្ដាលទេ ឈ្មោះ [redacted] ប៊ុនហាវ ពិតជាបានប្រព្រឹត្តមែន ដូចនេះសុំតុលាការតំកល់សាលក្រមកំបាំងមុខលេខ ៣៧ ខ ចុះថ្ងៃទី២៣-០៣-២០០៩នៅដដែល ។

-តំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋាន: សុំរក្សាបទចោទប្រកាន់នៅដដែល ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនរងគ្រោះ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាង

Scanned by CamScanner

-ក្រោយពីបានពិនិត្យ និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាដំបូងរាជធានីភ្នំពេញ**

-យល់ឃើញថាពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៣-០៤-២០០៩ របស់ឈ្មោះ [redacted] ប៊ុនហាវ ធ្វើឡើងតាមកំណត់ច្បាប់ សាលាដំបូងរាជធានីភ្នំពេញទទួលជំនុំជំរះបានតាមបញ្ញត្តិមាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថាជនជាប់ចោទបានទទួលដីកាកោះហើយតែមិនចូលខ្លួន តុលាការមិនលើកសវនាការបានទេ គឺជំនុំជំរះកំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថានាពេលសវនាការនេះជនជាប់ចោទពុំបាននាំយកភស្តុតាងណាថ្មី ដែលជុយពីភស្តុតាង មាននៅក្នុងសំណុំរឿងមកបញ្ជាក់ជាថ្មី ដែលជាហេតុនាំឱ្យតុលាការកែប្រែសេចក្តីមរេចរបស់ខ្លួនបានឡើយ ។

X-យល់ឃើញថារឿងក្តីនេះសាលាដំបូងរាជធានីភ្នំពេញបានលើកយកសំអាងហេតុមកបញ្ជាក់នៅក្នុងសាលក្រមកំបាំងមុខលេខ ៣៧ "ខ" ចុះថ្ងៃទី២៣-០៣-២០០៩រួចអស់ហើយ ដូចនេះសាលាដំបូងរាជធានីភ្នំពេញ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

-យល់ឃើញថាសាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ៣៧ "ខ" ចុះថ្ងៃទី២៣-០៣-២០០៩ ដែលសំរេចមកនោះមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និង អង្គច្បាប់ហើយ ដូចនេះគប្បីរក្សាទុកបានការដដែល ។

**<u>មោតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>ទិនិច្ឆ័យសេចក្តី</u>**

១-ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី២៣-០៤-២០០៩ របស់ឈ្មោះ [redacted] ប៊ុនហាវ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌកំបាំងលេខ ៣៧ "ខ" ចុះថ្ងៃទី២៣-០៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២៣-០៦-២០០៩ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ កំបាំងមុខជនជាប់ចោទ តែចាត់ទុកជាចំពោះមុខ មេធាវីការពារជនជាប់ចោទ ចំពោះមុខដើមបណ្តឹង មេធាវីដើមបណ្តឹង បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមជំនុំជំរះ |
|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ
ចៅក្រមជំនុំជំរះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
រាជធានីភ្នំពេញ ថ្ងៃទី 24 ខែ កក្កដា ឆ្នាំ ២០០៩
ក្រឡាបញ្ជី
[redacted]

Scanned by CamScanner